ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ សម្របសម្រួលជួយពលរដ្ឋខ្មែរ១៦នាក់ដែលត្រូវចាប់ខ្លួន

------------

ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃ បានរាយការណ៍ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពីការសម្របសម្រួលបញ្ហាពាក់ព័ន្ធនឹងករណីពលរដ្ឋខ្មែរ**១៦នាក់** ដែលត្រូវបានអាជ្ញាធរថៃចាប់ខ្លួនពីបទឆ្លងដែនចូលកាប់ឈើគ្រញូងដោយខុសច្បាប់ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ថា បន្ទាប់ពីទទួលបានព័ត៌មានពីការចាប់ខ្លួននេះ ស្ថានអគ្គកុងស៊ុល បានចាត់មន្ត្រីកុងស៊ុលជួបទំនាក់ទំនងជាមួយអាជ្ញាធរពាក់ព័ន្ធរបស់ថៃនិងពលរដ្ឋខ្មែរទាំង១៦នៅប៉ុស្តិ៍នគរបាលប៉ាងស៊ីដា ហើយទទួលបានព័ត៌មានដូចតទៅ៖

នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោងប្រមាណ០៨:៣០នាទី កងកម្លាំងអភិរក្សព្រៃឈើសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះល្បាតនៅតំបន់ឧទ្យានជាតិប៉ាងស៊ីដា ស្ថិតក្នុងភូមិបាក់ខាមីន ឃុំខូកពីខង ស្រុកមឿងសាកែវ ខេត្តសាកែវ ប្រទះឃើញមនុស្សមួយក្រុមមានគ្នាប្រមាណ២១នាក់ កំពុងដើររកកាប់ឈើ ហើយក៏បានឡោមព័ទ្ធឃាត់ខ្លួនពលរដ្ឋខ្មែរសរុបចំនួន**១៦នាក់** ដែលមានឈ្មោះដូចខាងក្រោម ដោយរឹបអូសបានវត្ថុតាងមួយចំនួន ដូចជា រណាយន្ត១គ្រឿង កាំភ្លើង១ដើម ទូរស័ព្ទដៃ៩គ្រឿង និងកាបូប២១៖

១. លោក ភិន ភឿង អាយុ ៥៥ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
២. លោក កង ឧត្តម អាយុ ២៥ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
៣. លោក ហឹម ប៊ុនធឿន អាយុ ២៥ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
៤. លោក ចាន់ ភាព អាយុ ២៥ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
៥. លោក ម៉ែ ស្មើ អាយុ ២៤ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
៦. លោក ស្ដើង សេន អាយុ ២២ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
៧. លោក ឃី ចន្ទ្រា អាយុ ២២ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
៨. លោក បៀវ ធឿន អាយុ ២៨ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
៩. លោក ញ៉ៅ សាន អាយុ ២៦ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
១០. លោក វើយ វឿន អាយុ ២១ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
១១. លោក អឿន វ៉ឺន អាយុ ២៧ ឆ្នាំ មកពីស្រុកសំឡូត ខេត្តបាត់ដំបង
១២. លោក ដក់ ជន អាយុ ៤០ ឆ្នាំ មកពីស្រុករតនមណ្ឌល ខេត្តបាត់ដំបង
១៣. លោក ថាន ភារៈ អាយុ ២៧ ឆ្នាំ មកពីស្រុករតនមណ្ឌល ខេត្តបាត់ដំបង
១៤. លោក ជ្រៃ បូរ៉ាន អាយុ ១៦ ឆ្នាំ មកពីស្រុករតនមណ្ឌល ខេត្តបាត់ដំបង
១៥. លោក សឺន រដ្ឋា អាយុ ៣១ ឆ្នាំ មកពីស្រុករតនមណ្ឌល ខេត្តបាត់ដំបង

១៦. លោក សឿន សារី អាយុ ៣១ ឆ្នាំ មកពីស្រុករតនមណ្ឌល ខេត្តបាត់ដំបង

ពលរដ្ឋខ្មែរទាំង១៦នាក់ ត្រូវបានបញ្ជូនទៅប៉ុស្តិ៍នគរបាលប៉ាងស៊ីដានៃខេត្តសាកែវ ដើម្បីសាកសួរនិងកសាងសំណុំរឿង រួចបញ្ជូនបន្តឲ្យទាហានឈុតខ្មៅថៃសាកសួរបន្ថែមទៀតពាក់ព័ន្ធនឹងការប្រើប្រាស់អាវុធ មុននឹងបញ្ជូនទៅតុលាការតាមនីតិវិធី។

នៅល្ងាចថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ សមត្ថកិច្ចថៃបានបញ្ជូនពលរដ្ឋខ្មែរខាងលើទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តសាកែវ។ តាមការជូនព័ត៌មានក្រៅផ្លូវការពីអាជ្ញាធរថៃ សំណុំរឿងនេះអាចមានស្ថានទម្ងន់ទោស ដោយសារពាក់ព័ន្ធនឹងការប្រើប្រាស់អាវុធខុសច្បាប់។

ស្ថានអគ្គកុងស៊ុល កំពុងសហការជាមួយអាជ្ញាធរពាក់ព័ន្ធរបស់ថៃ ព្រមទាំងរកមេធាវីថៃស្ម័គ្រចិត្តឲ្យជួយការពារក្តី ពេលឡើងតុលាការនាពេលខាងមុខ។

ភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ